**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៤៥៤៥ **អយក.**បន

រដ្ឋបាលទទួលលិខិតចូល
ចូល លេខ:៣៩៧១ ...
ថ្ងៃទី១..៨..១៧..ម៉ោង១០:១៧
បញ្ជូនទៅ:...........................

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៧

**ជម្រាបមក**

**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ** ៖ ការប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ។

**យោង** ៖ -លិខិតលេខ៤៨៧ មស.ក្រខ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ

-លិខិតលេខ៣០១៦អយក.បល ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា

-ប្រកាសលេខ៣៩ អយក.ប្រក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៩ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក លោកស្រីថា ក្នុងឆ្នាំ២០១៧នេះ ក្រសួងអប់រំ យុវជន និងកីឡា មានគម្រោងជ្រើសរើសគ្រូបង្រៀនកម្រិតមូលដ្ឋាន បង្រៀននៅអនុវិទ្យាល័យ ( ១២ + ២ )ចំនួន៦០០នាក់ រយៈពេលបណ្តុះបណ្តាល ២ឆ្នាំ ចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦។

សូមលោក លោកស្រី រៀបចំផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនបេក្ខជននៅតាមរាជធានី ខេត្ត របស់លោក លោកស្រីតាមការណែនាំដូចខាងក្រោម ៖

**I- លក្ខខណ្ឌជ្រើសរើស** ៖ ជ្រើសរើសក្នុងចំណោមបេក្ខជនទាំងពីរភេទដែល ៖

១-ជាសិស្សសុទ្ធសាធ មានសញ្ជាតិខ្មែរ មានជីវប្រវត្តិច្បាស់លាស់ មានសុខភាព និងកាយសម្បទាល្អ មិនទាន់មានការងារក្នុងក្របខ័ណ្ឌរដ្ឋ។ បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ញាបត្រ ចាប់ពីមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ ឬសញ្ញាបត្រដែលមានតម្លៃសមមូលឡើងទៅ ឬសញ្ញាបត្របច្ចេកទេសវិជ្ជាជីវៈកម្រិត៣ មានអាយុពី១៦ ដល់២៥ឆ្នាំ គិតដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧។

២-ជាគ្រូបឋមសិក្សា និងគ្រូមត្តេយ្យសិក្សា ដែលបានតែងតាំងស៊ប់ក្នុងក្របខណ្ឌ ហើយមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ ឬសញ្ញាបត្រដែលមានតម្លៃសមមូលឡើងទៅ។

៣-ជាគ្រូបឋមសិក្សា និងគ្រូមត្តេយ្យសិក្សា ដែលមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំណេះទូទៅ ឬជាគ្រូបឋមសិក្សា និងគ្រូមត្តេយ្យសិក្សា ដែលបានបំពេញរូបមន្ត ( ៧+១ ) ហើយមានអតីតភាពបម្រើការងារ៥ឆ្នាំយ៉ាងតិច។

**II- ការប្រឡងជ្រើសរើស** ៖ បេក្ខជនទាំងអស់ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើស។

១-កាលបរិច្ឆេទទទួលពាក្យសុំចុះឈ្មោះប្រឡង ៖ ចាប់ពីថ្ងៃប្រកាសផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៧។
២-សម័យប្រឡង ៖ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧។

៣-វិញ្ញាសាប្រឡង ៖ តាមកម្មវិធីថ្នាក់ទី១២ ចំណេះទូទៅ។

មុខវិជ្ជាឯកទេសនីមួយៗ ត្រូវប្រឡង ៣វិញ្ញាសា ដែលរួមមាន ៖

- វិញ្ញាសា វប្បធម៌ទូទៅ រយៈពេល ២ម៉ោង ( វិញ្ញាសារួមគ្រប់មុខវិជ្ជាឯកទេស ) មេគុណ១
- វិញ្ញាសាមុខវិជ្ជាឯកទេសទី១ រយៈពេល ២ម៉ោង មេគុណ២
- វិញ្ញាសាមុខវិជ្ជាឯកទេសទី២ រយៈពេល ២ម៉ោង មេគុណ១

៤-ទីកន្លែងប្រឡង ៖ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ ហ៊ុន សែនខេត្តកណ្តាល កំពង់ចាម បាត់ដំបង ព្រៃវែង និងតាកែវ។ ដោយឡែកបេក្ខជន ដែលជ្រើសរើសមុខវិជ្ជាឯកទេសភាសាបារាំង-គណិតវិទ្យា ភាសាបារាំង-រូបវិទ្យា ភាសាបារាំង-ជីវវិទ្យា កេរ្រ្តសាស្ត្រ-បសុវប្បកម្ម និងពាងជាង-អគ្គិសនី ត្រូវប្រឡងនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ។

៥- សំណុំលិខិតរបស់បេក្ខជន ៖ បេក្ខជនត្រូវបំពេញពាក្យសុំចុះឈ្មោះ និងសំណុំលិខិតទាំងអស់ ដោយផ្ទាល់ដៃ។

-ពាក្យសុំចុះឈ្មោះប្រឡង ..........................................................................................២ច្បាប់

-សញ្ញាបត្រ ឬវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃសមមូល ឬ សញ្ញាបត្របច្ចេកទេសវិជ្ជាជីវៈកម្រិត៣ (ករណីថតចម្លងត្រូវឱ្យច្បាស់ដូចច្បាប់ដើម ហើយបញ្ជាក់ និងប្រថាប់ត្រាពីអាជ្ញាធររាជធានី ខេត្ត។ ពេលដាក់ពាក្យសុំចុះឈ្មោះប្រឡងត្រូវភ្ជាប់ជាមួយនូវច្បាប់ដើម ដើម្បីផ្ទៀងផ្ទាត់).......១ច្បាប់

-ជីវប្រវត្តិសង្ខេប(គំរូភ្ជាប់) ..........................................................................................២ច្បាប់

-សលាកបត្រឯកត្តជនមានបិទរូបថតថ្មីទំហំ ៤x៦ មានស្នាមមេដៃស្តាំ និងហត្ថលេខារបស់បេក្ខជន(គំរូភ្ជាប់) ដោយប្រថាប់ត្រាមន្ទីរអយក.លើរូបថត) ..........................................................................................៣ច្បាប់

-ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសិស្សថ្នាក់ទី១២ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដោយមានប្រថាប់ត្រាពីអាជ្ញាធររាជធានី-ខេត្ត ដោយភ្ជាប់ជាមួយនូវច្បាប់ដើម ដើម្បីផ្ទៀងផ្ទាត់ពេលដាក់ពាក្យសុំចុះឈ្មោះប្រឡង............១ច្បាប់

-វិញ្ញាបនបត្របញ្ជាក់សុខភាព(បំពេញក្រោយប្រកាសលទ្ធផល១ខែយ៉ាងយូរ) ............................................១ច្បាប់

-លិខិតធានារបស់ឪពុកម្តាយ ឬអាណាព្យាបាល(ចំពោះបេក្ខជនជាសិស្ស) (គំរូភ្ជាប់) ..................................២ច្បាប់

-កិច្ចសន្យាស្ម័គ្រចិត្តបម្រើវិស័យអប់រំ រយៈពេល១០ឆ្នាំ(ចំពោះបេក្ខជនជាសិស្ស) (គំរូភ្ជាប់)..........................២ច្បាប់

-វិញ្ញាបនបត្រវដ្តបាល បញ្ជាក់ដោយក្រសួង/មន្ទីរ(ចំពោះបេក្ខជនជាគ្រូមត្តេយ្យសិក្សា ឬគ្រូបឋមសិក្សា)(គំរូភ្ជាប់).....២ច្បាប់

-រូបថតថ្មី ថតចំពីមុខ គ្មានពាក់មួក គ្មានពាក់វ៉ែនតា គ្មានសក់បាំងត្រចៀក ទំហំ(៤x៦) ..............................២សន្លឹក

-បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង(២០០០៛)..........................................................................................១ច្បាប់

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដែលមានមជ្ឈមណ្ឌលគរុកោសល្យភូមិភាគត្រូវរក្សាទុកសំណុំលិខិតសុំចុះឈ្មោះប្រឡងរបស់បេក្ខជនម្នាក់១ច្បាប់។

## III-ភារកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

១- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវ ៖

-រៀបចំផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងទទួលពាក្យសុំចុះឈ្មោះប្រឡងរបស់បេក្ខជនគ្រប់មុខវិជ្ជាឯកទេសឱ្យទាន់ពេលវេលា។

-ផ្តល់សំណុំលិខិតសុំចុះឈ្មោះប្រឡងរបស់បេក្ខជន ដោយឥតគិតថ្លៃ។

-ចាត់តាំងគណៈកម្មការទទួលពាក្យសុំចុះឈ្មោះប្រឡងរបស់បេក្ខជន។

-ណែនាំបេក្ខជនឱ្យបំពេញសំណុំលិខិតឱ្យបានគ្រប់គ្រាន់ ដោយផ្ទាល់ដៃ និងផ្តិតស្នាមមេដៃស្តាំឱ្យត្រឹមត្រូវបំផុត នៅចំពោះមុខគណៈកម្មការទទួលពាក្យសុំចុះឈ្មោះប្រឡង។

-ពិនិត្យសំណុំលិខិតរបស់បេក្ខជនឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌជ្រើសរើស រួចផ្ញើទៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដែលមានមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ក្នុងភូមិភាគរបស់ខ្លួនឱ្យបានមុន ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧។ ដោយឡែកសំណុំលិខិតរបស់បេក្ខជនដែលជ្រើសរើសមុខវិជ្ជាឯកទេស ភាសាបារាំង-គណិតវិទ្យា ភាសាបារាំង-រូបវិទ្យា ភាសាបារាំង-ជីវវិទ្យា ក្សេត្រសាស្ត្រ-បសុវប្បកម្ម និងពាងជាង-អគ្គិសនី ត្រូវផ្ញើទៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ តាមកាលបរិច្ឆេទខាងលើដែរ។

-ប្រមូលប្រាក់បង់សិទ្ធិប្រឡងរបស់បេក្ខជនក្នុងម្នាក់ពីរពាន់រៀល (២០០០៛) ហើយបង់ចូលថវិការដ្ឋ តាមបែបបទហិរញ្ញកិច្ច និងបញ្ជូនប័ណ្ណបង់ប្រាក់ចេញដោយរតនាគាររាជធានី ខេត្ត ទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ) យ៉ាងយូរ១៥ថ្ងៃ ក្រោយការប្រឡង។

-ប្រគល់សលាកបត្រឯកត្តជនមួយច្បាប់ឱ្យទៅបេក្ខជន ក្រោយពេលពិនិត្យសំណុំលិខិតត្រឹមត្រូវ និងប្រថាប់ត្រាលើរូបថតបេក្ខជន សម្រាប់បេក្ខជនបង្ហាញអនុរក្សនៅពេលចូលប្រឡង។

២- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដែលមានមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ត្រូវ ៖

+ទទួលសំណុំលិខិតរបស់បេក្ខជន ដែលរាជធានី ខេត្ត ក្នុងភូមិភាគរបស់ខ្លួនបានផ្ញើជូន។ បន្ថែមលើនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ត្រូវទទួលសំណុំលិខិតរបស់បេក្ខជនជ្រើសរើសមុខវិជ្ជាឯកទេសភាសាបារាំង-រូបវិទ្យា ភាសាបារាំង-គណិតវិទ្យា ភាសាបារាំង-ជីវវិទ្យា ក្សេត្រសាស្ត្រ-បសុវប្បកម្ម និងពាងជាង-អគ្គិសនី ដែលផ្ញើមកពីគ្រប់ខេត្ត។

+ព្រាងលិខិតឧទ្ទេសនាម គណៈមេប្រយោគ សម្រាប់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគរបស់ខ្លួន ( គណៈមេប្រយោគ ០៤នាក់ក្នុង០១មណ្ឌល គណៈកម្មការកណ្តាល០,៣៥នាក់/បន្ទប់ អនុរក្ស ២,៤០នាក់/ បន្ទប់)។ សមាសភាពគណៈមេប្រយោគរួមមាន មន្ត្រីមន្ទីរមុខងារសាធារណៈចំនួន០២នាក់ មន្ត្រីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡា ដែលទទួលបន្ទុកការងារបណ្តុះបណ្តាល ផ្នែកមធ្យមសិក្សា មន្ត្រីសាលាគរុកោសល្យរាជធានី ខេត្ត ដោយបញ្ជាក់ច្បាស់ពីក្របខ័ណ្ឌ មុខងារ និងមុខវិជ្ជាឯកទេសរបស់បុគ្គលម្នាក់ៗ ហើយផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា ( នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ) ឱ្យបានមុនថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៧ ជាមួយនឹងចំនួនបេក្ខជន ចំនួនបន្ទប់ តាមមុខវិជ្ជាឯកទេស ដែលបានដាក់ពាក្យសុំចុះឈ្មោះប្រឡង។

+រៀបចំសំណុំលិខិតបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា ក្រោយពេលបញ្ចប់វិញ្ញាសាសរសេរ ៖

១-តារាងស្រង់ពិន្ទុតាមបន្ទប់ក្នុងមួយបន្ទប់......................................................................................២ច្បាប់

២-បញ្ជីរាយនាមបេក្ខជន តាមមុខវិជ្ជាឯកទេស តាមបន្ទប់ តាមរាជធានី ខេត្ត តាមឆ្នាំជាប់សញ្ញាបត្រ
និងតាមអក្ខរក្រម(ស្រៈ និងព្យញ្ជនៈ)ក្នុងមួយបន្ទប់(គំរូភ្ជាប់)..........................................................៣ច្បាប់

៣-កម្រងសលាកបត្រឯកត្តជន(តាមលំដាប់លេខរៀងក្នុងបញ្ជី).............................................................. ១ច្បាប់

៤-កម្រងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសិស្សថ្នាក់ទី១២ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ..............................១ច្បាប់

៥-សំណុំលិខិតសុំចុះឈ្មោះប្រឡងរបស់បេក្ខជនម្នាក់ៗ ....................................................................១ច្បាប់

## IV- បំណែងចែកគរុសិស្សតាមរាជធានី ខេត្ត

| ល.រ | រាជធានី-ខេត្ត | គណិត រូប. | រូប. គីមី. | ជីវ. ផែនដី. | ប្រវត្តិ ភូមិ. | ខ្មែរ សីល.៣ | ក្សេត្រសាស្ត្រ បសុវប្បកម្ម | ជាងដាង អគ្គិសនី | បារាំង គណិត. | បារាំង រូប. | បារាំង ជីវ. | ICT អង់គ្លេស | អង់គ្លេស ខ្មែរ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | | | | | | | | ១ | ១ | ១ | | | ៣ |
| ២ | ស្ទឹងត្រែង | | ៤ | ២ | ៣ | | ១ | ១ | | | | ២ | ១២ | ២៥ |
| ៣ | ព្រះវិហារ | | ១ | ៣ | ៣ | | ១ | ១ | | | | ២ | ១២ | ២៣ |
| ៤ | កោះកុង | | ២ | ១ | | | | | | | | ២ | ១១ | ១៦ |
| ៥ | រតនគិរី | | | ១ | | | | | | | | ២ | ១១ | ១៤ |
| ៦ | មណ្ឌលគិរី | | ១ | ១ | ២ | | | | | | | ២ | ៩ | ១៥ |
| | | | ៨ | ៨ | ៨ | | ២ | ២ | ១ | ១ | ១ | ១០ | ៥៥ | ៩៦ |
| ៧ | កណ្ដាល | ៤ | | | | | | | ១ | ១ | ១ | ៣ | ១២ | ២២ |
| ៨ | កំពង់ឆ្នាំង | ៣ | | | | | | | | | | ៣ | ៩ | ១៥ |
| ៩ | កំពង់ស្ពឺ | ៣ | | | | | | | | | | ៣ | ៩ | ១៥ |
| | | ១០ | | | | | | | ១ | ១ | ១ | ៩ | ៣០ | ៥២ |
| ១០ | បាត់ដំបង | | | ៣ | | ២ | ១ | ១ | ២ | ២ | ២ | ៣ | ១៩ | ៣៥ |
| ១១ | ពោធិ៍សាត់ | | | ២ | | ១ | | | | | | ១ | ៩ | ១៣ |
| ១២ | បន្ទាយមានជ័យ | ២ | | | | | | | | | | ២ | ១១ | ១៥ |
| ១៣ | សៀមរាប | ៧ | | ៥ | | ៥ | ១ | ១ | ១ | ១ | ១ | ៣ | ២៥ | ៥០ |
| ១៤ | ឧត្ដរមានជ័យ | ១ | | | | | | | | | | ១ | ១៥ | ១៧ |
| ១៥ | ប៉ៃលិន | | | | | ២ | | | | | | ១ | ៨ | ១១ |
| | | ១០ | | ១០ | | ១០ | ២ | ២ | ៣ | ៣ | ៣ | ១១ | ៨៧ | ១៤១ |
| ១៦ | កំពង់ចាម | ៣ | ៤ | ២ | ២ | | ១ | ១ | ២ | ២ | ២ | ៣ | ២៥ | ៤៧ |
| ១៧ | ត្បូងឃ្មុំ | ៨ | ៥ | ៦ | ៦ | | | | | | | ៣ | ៣៤ | ៦២ |
| ១៨ | កំពង់ធំ | ១ | ១ | ១ | | | ១ | ១ | | | | ២ | ១២ | ១៩ |
| ១៩ | ក្រចេះ | | | ១ | ១ | | | | | | | ២ | ៩ | ១៣ |
| | | ១២ | ១០ | ១០ | ៩ | | ២ | ២ | ២ | ២ | ២ | ១០ | ៨០ | ១៤១ |
| ២០ | ព្រៃវែង | ៧ | | | | | ១ | ១ | | | | ៥ | ១៩ | ៣៣ |
| ២១ | ស្វាយរៀង | ២ | | | | | ១ | ១ | | | | ៣ | ១១ | ១៨ |
| | | ៩ | | | | | ២ | ២ | | | | ៨ | ៣០ | ៥១ |
| ២២ | តាកែវ | ៥ | ៦ | ៦ | | ៨ | | | ២ | ២ | ២ | ៥ | ៣១ | ៦៧ |
| ២៣ | កំពត | ១ | ២ | ២ | | ១ | | | | | | ២ | ១២ | ២០ |
| ២៤ | ព្រះសីហនុ | | | | | ១ | ១ | ១ | ១ | ១ | ១ | ២ | ៩ | ១៧ |
| ២៥ | កែប | ៤ | | | | | ១ | ១ | | | | ១ | ៨ | ១៥ |
| | | ១០ | ៨ | ៨ | | ១០ | ២ | ២ | ៣ | ៣ | ៣ | ១០ | ៦០ | ១១៩ |
| សរុបរួម | | ៥១ | ២៦ | ៣៦ | ១៧ | ២០ | ១០ | ១០ | ១០ | ១០ | ១០ | ៥៨ | ៣៨២ | ៦០០ |

**កំណត់សម្គាល់**

+មជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ ៖ បណ្តុះបណ្តាលជូនរាជធានីភ្នំពេញ ខេត្តកោះកុង ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងព្រះវិហារ ។

+មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល ៖ បណ្តុះបណ្តាលជូនខេត្តកណ្តាល កំពង់ឆ្នាំង និង កំពង់ស្ពឺ។

+មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ ៖ បណ្តុះបណ្តាលជូនខេត្តតាកែវ កំពត កែប និងព្រះសីហនុ។

+មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តបាត់ដំបង ៖ បណ្តុះបណ្តាលជូនខេត្តបាត់ដំបង ពោធិ៍សាត់ បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងប៉ៃលិន។

+មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ៖ បណ្តុះបណ្តាលជូនខេត្តកំពង់ចាម ត្បូងឃ្មុំ កំពង់ធំ និងក្រចេះ។

+មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង ៖ បណ្តុះបណ្តាលជូនខេត្តព្រៃវែង និងស្វាយរៀង។

+វិទ្យាស្ថានជាតិអប់រំ ៖ បណ្តុះបណ្តាលមុខវិជ្ជាឯកទេសភាសាបារាំង-រូបវិទ្យា ភាសាបារាំង-គណិតវិទ្យា ភាសាបារាំង-ជីវវិទ្យា សម្រាប់គ្រប់រាជធានី ខេត្ត។

+វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល ៖ បណ្តុះបណ្តាលមុខវិជ្ជាឯកទេស កសិកម្ម-សេដ្ឋកិច្ចសាស្ត្រ-បសុវប្បកម្ម និងរោងជាង-អគ្គិសនី សម្រាប់គ្រប់រាជធានី ខេត្ត។

+**ចំពោះអតីតគរុសិស្ស និស្សិត ដែលធ្លាប់បានលុបឈ្មោះចេញពីបញ្ជី និងអតីតបេក្ខជន ដែលធ្លាប់មានករណីក្នុងការប្រឡងកន្លងមក ពុំអនុញ្ញាតឱ្យដាក់ពាក្យសុំចុះឈ្មោះប្រឡងជាដាច់ខាត ( បញ្ជីរាយនាមជូនភ្ជាប់ )។**

+មិនអនុញ្ញាតឱ្យបេក្ខជនមកពីក្រៅរាជធានី ខេត្ត របស់ខ្លួនដាក់ពាក្យសុំចុះឈ្មោះប្រឡងឡើយ លើកលែងតែបេក្ខជនដែលជ្រើសរើសមុខវិជ្ជាឯកទេស កសិកម្ម-សេដ្ឋកិច្ចសាស្ត្រ-បសុវប្បកម្ម និងរោងជាង-អគ្គិសនី។

+ក្រសួងអប់រំ យុវជន និងកីឡា ពុំអនុញ្ញាតឱ្យគរុសិស្ស មត្តេយ្យសិក្សា បឋមសិក្សា និងកម្រិតមូលដ្ឋានដែលកំពុងបណ្តុះបណ្តាលនៅតាមសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សាលាគរុកោសល្យ និងវិក្រឹតការ រាជធានី ខេត្ត និង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគដាក់ពាក្យសុំចុះឈ្មោះប្រឡងឡើយ។

+ក្រសួងអប់រំ យុវជន និងកីឡា មិនទទួលពិនិត្យសំណុំលិខិតរបស់បេក្ខជនទាំងឡាយណា ដែលមានរូបថតលើសញ្ញាបត្រខ្មៅមើលមិនច្បាស់ សលាកបត្រឯកត្តជនគ្មានស្នាមមេដៃស្តាំរបស់បេក្ខជន សំណុំលិខិតមិនគ្រប់គ្រាន់ ក្លែងបន្លំ ឬបំពេញមិនបានត្រឹមត្រូវតាមការណែនាំខាងលើ។ **មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវទទួលខុសត្រូវ ចំពោះមុខបេក្ខជន និងក្រសួងក្នុងករណីមានបញ្ហាខាងលើនេះកើតឡើង ។**

+ពេលចូលប្រឡង បេក្ខជនត្រូវយកជាប់ជាមួយនូវ សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសិស្សថ្នាក់ទី១២ ឬ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ទាំងពីរជាដាច់ខាត ( ច្បាប់ដើម ) ដើម្បីបង្ហាញអនុរក្ស។

អាស្រ័យហេតុនេះ សូមលោក លោកស្រី ប្រធានអនុវត្តការងារនេះឱ្យទទួលបានលទ្ធផលល្អប្រសើរ។

សូមលោក លោកស្រីទទួលនូវការរាប់អានពីខ្ញុំ ។

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-គ្រប់សាលាខេត្ត និងរាជធានីភ្នំពេញ
" ដើម្បីសូមជ្រាបជាព័ត៌មាន "
-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
" ដើម្បីជាព័ត៌មាន និងជួយផ្សព្វផ្សាយ "
-កាលប្បវត្តិ-ឯកសារ ៖ នា.បវ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន